## II- ទីស្ដីការគណៈរដ្ឋមន្ត្រី

### ១— អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យ**

**លេខ ០៣ អនក្រ.បក**

**ស្ដីពីការបង្កើតស្ថានឯកអគ្គរាជទូត**

**នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីន ដោយមាននិវេសនដ្ឋាននៅក្រុង ម៉ានីល ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាព ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់ ។

មាត្រា ៥ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

# អនុក្រឹត្យ

## លេខ ០៤ អនក្រ.បក

## ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហព័ន្ធម៉ាឡេស៊ី ដោយមាននិវេសនដ្ឋាននៅក្រុងកូឡាឡាំពួរ ។

**មាត្រា ២ :** ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជ ទូតវិសាមញ្ញនិងពេញសមត្ថភាព ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយនឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់ ។

មាត្រា ៥ : អនុព័ន្ធយោធាមួយនាក់ ត្រូវជ្រើសតាំងដោយក្រសួងការពារប្រទេស ។

មាត្រា ៦ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រីនិងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីការពារប្រទេស រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ០៥ អនក្រ.បក.**

**ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃ**

**ព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋសឹង្ហបុរី**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសឹង្ហបុរី ដោយមាននិវេសនដ្ឋាន់នៅក្រុងសឹង្ហបុរី ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព ឬ ជាអគ្គទីប្រឹក្សា និងជាភារ ធារី ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយ នាក់ទៅពីរនាក់ ។

មាត្រា ៥ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្ថលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *